# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ: ១០៩ "ឃ១"

ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២០

-សំណុំរឿងរដ្ឋប្បវេណីលេខ: ១២៥៤

ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង០៩ព្រឹក នៅសាលសវនាការទី៥ លើសំណុំរឿងរដ្ឋប្បវេណីលេខ: ១២៥៤ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ដោយមានសមាសភាព៖

### ចៅក្រមជំនុំជម្រះ

-លោក [redacted] ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជី

-លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-រវាងដើមចោទឈ្មោះ [redacted] អប្សរីដា ភេទស្រី កើតថ្ងៃទី ២៤ ខែមីនា ឆ្នាំ១៩៩២ សញ្ជាតិខ្មែរ មុខរបរ បុគ្គលិកក្រុមហ៊ុន មានទីកន្លែងកំណើត [redacted] និងអាសយដ្ឋានស្ថិតបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] តារាវិទ្ធ (រស់) ម្ដាយឈ្មោះ [redacted] សុម៉ាលី (រស់)ប្ដីឈ្មោះ [redacted] ហេងលី កូន(គ្មាន)។

-អ្នកតំណាងដោយអាណត្តិមានមេធាវី [redacted]។

-និងចុងចម្លើយឈ្មោះ [redacted] ហេងលី ភេទប្រុស កើតថ្ងៃទី ២៩ ខែឧសភា ឆ្នាំ១៩៩១ សញ្ជាតិ អាមេរិក មុខរបរ បុគ្គលិកក្រុមហ៊ុន មានអាសយដ្ឋាននៅផ្ទះលេខ [redacted] ម្ដាយឈ្មោះ [redacted] សុមនិ (រស់) ប្រពន្ធឈ្មោះ [redacted] អប្សរីដា កូន(គ្មាន)។

-អ្នកតំណាងដោយអាណត្តិ (គ្មាន)។

### I.អង្គហេតុ និងចំណុចវិវាទ

១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

-ប្ដឹងសុំសាលក្រមលែងលះប្ដី ឈ្មោះ [redacted] ហេងលី អាយុ ២៨ឆ្នាំ។

២.ការពន្យល់ត្រួសៗអំពីរឿងក្ដី

តាមពាក្យបណ្ដឹងចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់ដើមចោទឈ្មោះ [redacted] អប្សរីដា បានបញ្ជាក់ថា: ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយ និងប្ដីឈ្មោះ [redacted] ហេងលី តាមប្រពៃណីខ្មែរនៅក្នុងអំឡុងខែតុលា ឆ្នាំ២០១៨ ខ្លួននិងប្ដីបានចុះសំបុត្រពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ៧៩ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅសាលាសង្កាត់ផ្សារដើមគរ រាជធានីភ្នំពេញ។ ក្រោយពីរៀបការរួច ខ្លួននិងប្ដីបានរួមរស់ជាមួយគ្នា



Scanned with CamScanner

អស់រយៈពេលប្រហែល១ខែ ហើយប្ដីរបស់ខ្លួនក៏ត្រលប់ទៅប្រទេសទៅធ្វើការនៅប្រទេសអាមេរិក វិញដោយគាត់សន្យាថានឹងចេញចូលមកប្រទេសកម្ពុជា ប៉ុន្តែក្រោយពេលដែលប្ដីខ្លួនទៅដល់ប្រទេសអាមេរិកវិញ ជីវិតគ្រួសារក៏ចាប់លែងសួរសុខទុក្ខគ្នាទៅវិញទៅមកអស់រយៈពេលជាងកន្លះឆ្នាំហើយ។ ទើបខ្លួនសម្រេចចិត្តដាក់ពាក្យបណ្ដឹងសុំលែងលះជាមួយនិងប្ដីឈ្មោះ [redacted] ហេងលី តាមផ្លូវច្បាប់។

៣.អង្គហេតុដែលអះអាងដោយដើមចោទ [redacted] អប្សរីដា ភេទស្រី បានធ្វើសេចក្ដីថ្លែងការណ៍ថា៖

ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយ ភាគីចុងចម្លើយឈ្មោះ [redacted] ហេងលី តាមប្រពៃណីខ្មែរនៅក្នុងអំឡុងខែតុលា ឆ្នាំ២០១៨ ខ្លួននិងបានទៅចុះសំបុត្រពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ៧៩ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅសាលាសង្កាត់ផ្សារដើមគរ។ ក្រោយពីរៀបការរួច ខ្លួននិងប្ដីបានរួមរស់ជាមួយគ្នារយៈពេលប្រហែល១ខែហើយប្ដីរបស់ខ្លួនក៏ត្រលប់ទៅប្រទេសទៅធ្វើការនៅប្រទេសអាមេរិកវិញដោយគាត់សន្យាថានឹងចេញចូលមកប្រទេសកម្ពុជាមកមើលថែខ្លួន ប៉ុន្តែក្រោយពេលដែលប្ដីខ្លួនបានទៅដល់ប្រទេសអាមេរិកវិញ ជីវិតគ្រួសារខ្លួននិងប្ដីក៏ចាប់ផ្ដើមប្រេះឆាមានជំលោះពាក្យសំដី រហូតឈានដល់ការផ្ដាច់ទំនាក់ទំនង លែងនិយាយលែងសួរសុខទុក្ខគ្នាទៅវិញទៅមកអស់រយៈពេលជាងកន្លះឆ្នាំហើយមកទល់ពេលនេះ ទើបខ្លួនសម្រេចចិត្តដាក់ពាក្យបណ្ដឹងសុំលែងលះជាមួយនិងប្ដីឈ្មោះ [redacted] ហេងលី។ ចំពោះកូន គ្មាន, ទ្រព្យសម្បត្តិរួម និងបំណុលរួមគ្មាន នោះទេអំឡុងពេលដែលពួកខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ។ ហើយខ្លួន និងភាគីចុងចម្លើយឈ្មោះ [redacted] ហេងលី បានព្រមព្រៀងផ្ដិតមេដៃលើកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៩ ដែលមានសាក្សីដឹងលឺ ចំនួន ២នាក់បានឯកភាពលើការរំលាយចំណងអាពាហ៍ពិពាហ៍រវាងរូបខ្លួននិងភាគីចុងចម្លើយ តាមផ្លូវច្បាប់ដោយពុំមានការបង្ខិតបង្ខំពីភាគីណាឡើយ សូមតុលាការមេត្តាចេញសាលក្រមឲ្យខ្លួន និងចុងចម្លើយបានលែងលះតាមច្បាប់ផង។

-មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ សុំតុលាការសម្រេចតាមការទាមទាររបស់កូនក្ដីខ្លួន ផងព្រោះគូភាគីទាំងពីរពិតជាអស់មនោសញ្ចេតនារួមរស់ជាមួយគ្នាពិតមែន។ ហើយពួកគាត់ពិជាបានផ្ដិតមេដៃលើកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៩ ប្រាកដមែន។

៤.អង្គហេតុដែលអះអាងដោយចុងចម្លើយ

ភាគីចុងចម្លើយឈ្មោះ [redacted] ហេងលី ភេទប្រុស អាយុ ២៨ឆ្នាំ ដែលបច្ចុប្បន្នកំពុងរស់នៅសហរដ្ឋអាមេរិក បានទទួលដីកាកោះរបស់សាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ដើម្បីឲ្យចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ លើបណ្ដឹងសុំលែងលះរបស់ភាគីដើមចោទឈ្មោះ [redacted] អប្សរីដា ដោយក្រឡាបញ្ជីបានធ្វើការបញ្ជូនដីកាកោះនេះតាមរយៈក្រុមហ៊ុន [redacted] ទៅដល់អាស័យដ្ឋានភាគីចុងចម្លើយបានផ្ដិតមេដៃទទួលលើដីកាកោះនោះរួច។ ហើយនៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៩ ភាគីចុងចម្លើយ និងភាគីដើមចោទបានព្រមព្រៀងគ្នាចុះកិច្ចព្រមព្រៀងលែងលះដែលមានសាក្សីពីរនាក់ចូលរួមដឹងលឺ និងមានភស្តុតាងជាវីដេអូឃ្លីប ដែលបានដាក់បញ្ចូលភស្តុតាងមកក្នុងសំណុំរឿងនេះផងដែរ ដោយបញ្ជាក់ថាភាគីដើមចោទ និងចុងចម្លើយ ពិតជាមានឆន្ទៈក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍អ្នកទាំងពីរតាមច្បាប់ពិតមែន ហើយភាគីចុងចម្លើយបានបញ្ជាក់ថា ខ្លួនឯកភាពលើការប្ដឹងសុំលែងលះ របស់ឈ្មោះ [redacted] អប្សរីដា ខ្លួនមិនជំទាស់អ្វីនោះទេ ចំពោះកូនគ្មាន,ទ្រព្យសម្បត្តិរួមគ្មាន និងបំណុលរួមគ្មាន។

តុលាការបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ៩ព្រឹកនោះ ក្រោយពីបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួច ក្រឡាបញ្ជីបានធ្វើការបញ្ជូនកំណត់ហេតុស្ដីពីនីតិវិធីត្រៀមនោះទៅឲ្យភាគីចុងចម្លើយឈ្មោះ [redacted] ហេងលី អាសយដ្ឋាននៅសហរដ្ឋអាមេរិកម្ដងទៀតតាមរយៈក្រុមហ៊ុន [redacted] ដដែល។ លុះដល់ថ្ងៃទី ០៩ ខែតុលា ឆ្នាំ

២០១៩ ក្រឡាបញ្ជីបានធ្វើការបញ្ជូនដីកាកោះអញ្ជើញ ភាគីចុងចម្លើយម្តងទៀតឲ្យចូលរួមនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងលែងលះខាងលើ ឲ្យគូភាគីចូលរួមនៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ៩ព្រឹក នៅសាលសវនាការទី៤ នៃសាលាដំបូងរាជធានីភ្នំពេញ បានធ្វើការបញ្ជូនតាមរយៈក្រុមហ៊ុនដឹ[redacted]ទៅដល់ផ្ទះរបស់ភាគីចុងចម្លើយ [redacted] ហេងលី ហើយដីដូនរបស់ឈ្មោះ [redacted] ហេងលី បានផ្តិតមេដៃទទួលជំនួសលើរបាយការណ៍បញ្ជូនដីកោះអញ្ជើញនោះ ដល់កាលកំណត់នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគីចុងចម្លើយអវត្តមានដោយខ្លួនស្នើសុំឲ្យតុលាការសម្រេចតាមនីតិវិធីច្បាប់ ព្រោះខ្លួនបានព្រមព្រៀងលែងលះជាមួយភាគីដើមចោទហើយមិនមានអ្វីជំទាស់លើការប្តឹងសុំនេះទេ ដោយមានកិច្ចព្រមព្រៀងលែងលះចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៩ តុលាការបានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងជូនដំណឹងពីកំណត់ហេតុទាញហេតុផលម្តងទៀតទៅភាគីចុងចម្លើយ [redacted] ហេងលី ឲ្យបានដឹង។

**៥.ចំណុចគ្មានវិវាទ (គ្មាន)។**

**៦.ចំណុចវិវាទ**

១-តើដើមចោទប្តឹងសុំលែងលះពីចុងចម្លើយ ត្រឹមត្រូវតាមផ្លូវច្បាប់ដែរឬទេ?

## II.ការពិនិត្យភស្តុតាង

**១-ភស្តុតាងជាឯកសាររបស់ដើមចោទ**

-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខៈ ៧៦ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ចេញដោយសាលាសង្កាត់ផ្សារដើមគរ រាជធានីភ្នំពេញ។

-អត្តសញ្ញាណប័ណ្ណរបស់ដើមចោទ លេខៈ [redacted]ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ (ថតចម្លង)។

- អត្តសញ្ញាណប័ណ្ណរបស់ចុងចម្លើយ លេខៈ [redacted]ះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៤ (ថតចម្លង)។

-កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៩។

-ប្រដាប់ផ្ទុកឯកសារ (USB Flash) ចំនួន ១ ។

**២-ភស្តុតាងជាឯកសាររបស់ចុងចម្លើយ**

-កិច្ចព្រមព្រៀង ចុះទី២០ ខែតុលា ឆ្នាំ២០១៩ ។

## <u>សំអាងហេតុ</u>

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១-ភាគីដើមចោទ និងភាគីចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីខ្មែរ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ប្រាកដមែន ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ៧៩ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩ ។ ដើមចោទ និងចុងចម្លើយ ពិតជាបានបំពេញលក្ខខណ្ឌស្របទៅនឹងមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី ដែលកំណត់ថាភាគីដើមចោទ និងភាគីចុងចម្លើយ គឺជាប្តីប្រពន្ធស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជាប្រាកដមែន។

២-ដើមចោទបានដាក់ពាក្យបណ្តឹងមកតុលាការ ដោយទាមទារសុំឲ្យតុលាការចេញសាលក្រមឲ្យខ្លួនបានលែងលះពីចុងចម្លើយ ដោយលើកមូលហេតុថាខ្លួននិងចុងចម្លើយរស់នៅមិនចុះសម្រុងនឹងគ្នា ម្យ៉ាងវិញទៀតចុងចម្លើយបានបែកលំនៅដ្ឋានទៅរស់នៅសហរដ្ឋអាមេរិកតាំងពីឆ្នាំ២០១៨មកមានរយៈពេល២ឆ្នាំហើយ ដល់បច្ចុប្បន្ននេះជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាបន្តទៀត ទើបខ្លួនដាក់ពាក្យបណ្តឹងមកតុលាការសុំឲ្យចៅក្រមចេញសាលក្រមឲ្យខ្លួនបានលែងលះពីចុងចម្លើយតាមច្បាប់ផង។ ចំណុចនេះតុលាការ ពិចារណាឃើញថាការលើកឡើងនិងការទាមទារលែងលះរបស់ដើមចោទ មានលក្ខណៈសមរម្យស្របនឹងមាត្រា ៩៧៨ ចំណុច “ង” នៃក្រមរដ្ឋប្បវេណី ដូច្នេះចំណុចនេះគប្បីតុលាការលើកយកមកពិចារណា។



Scanned with CamScanner

៤-ផ្អែកតាមលទ្ធផល នៃការបញ្ជូនដីកាកោះទៅចុងចម្លើយ និងភស្តុតាងជាវីដេអូឃ្លីប បានបញ្ជាក់ឲ្យឃើញថា ចុងចម្លើយពិតជាបានយល់ព្រមលែងលះជាមួយនិងដើមចោទប្រាកដមែន។ ម្យ៉ាងវិញទៀត គូភាគីបានអះអាងថាខ្លួនទាំងពីរនាក់មិនមានទ្រព្យសម្បត្តិរួម និងបំណុលរួមក្នុងអំឡុងពេលរស់នៅជាមួយគ្នាទេ ហើយពួកខ្លួនទាំងពីនាក់ក៏មិនមានកូនដែរ។ ចំណុចនេះ តុលាការពិចារណាឃើញថាការលើកមូលហេតុរបស់ដើមចោទមានលក្ខណៈសមរម្យ ដែលបង្ហាញឲ្យឃើញថាទំនាក់ទំនងរវាងដើមចោទនិងចុងចម្លើយ ត្រូវបានបែកបាក់គ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបានឡើយ។ម្យ៉ាងវិញទៀតបើអនុញ្ញាតឲ្យដើមចោទ និងចុងចម្លើយលែងលះនឹងគ្នាក៏ពុំមានស្ថានភាពដែលបង្កឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរចំពោះភាគីណាមួយឡើយ ហេតុដូច្នេះគប្បីតុលាការសម្រេចតាមការស្នើសុំរបស់ដើមចោទ។

៥-ប្រាក់ប្រដាប់ក្តី គប្បីអនុវត្តតាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ក្រោយពីបានពិនិត្យលើភស្តុតាងនានា ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងក្រោយពីបានពិចារណារួចហើយ៖

## សេចក្តីសម្រេចបញ្ចប់

១.ឲ្យដើមចោទឈ្មោះ [redacted] អប្សរាវីដា ភេទស្រី អាយុ ២៩ឆ្នាំ លែងលះពីចុងចម្លើយឈ្មោះ [redacted] ហេងលី ភេទប្រុស អាយុ ២៨ឆ្នាំ តាមការព្រមព្រៀងរបស់គូភាគី។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ចំពោះមុខភាគីដើមចោទ និងកំបាំងមុខភាគីចុងចម្លើយ ប្រកាសជាអសាធារណៈនៅថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២០។

គូភាគីមានសិទ្ធិប្តឹងជំទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃបានទទួលសាលក្រមនេះ៕

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ អង្គារ៍ ៤កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

[redacted]

[redacted]



Scanned with CamScanner